# សភាអឺរ៉ុបអនុម័តផែនទីបង្ហាញផ្លូវដោះស្រាយ វិបត្តិសុខភាពនាពេលអនាគត




លោកស្រី Roberta Metsola ប្រធានសភាអឺរ៉ុប

XINHUANET ថ្ងៃសុក្រ ១២រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣

រាជធានីព្រុចស៊ែល៖ កាលពីថ្ងៃព្រហស្បតិ៍ ទី១៣ ខែកក្កដា ឆ្នាំ២០២៣ សភាអឺរ៉ុប(EP)បានអនុម័តរបាយការណ៍មួយជាមួយនឹងផែនទីបង្ហាញផ្លូវដ៏ច្បាស់លាស់មួយស្តីពីមធ្យោបាយ ក្នុងការដោះស្រាយវិបត្តិសុខភាពនាពេលអនាគត ដោយផ្អែកលើមេរៀនទទួលបានពីជំងឺរាតត្បាតជាសកលកូវីដ-១៩។ សភាអឺរ៉ុបបានចេញសេចក្តីថ្លែងការណ៍មួយថា សមាជិកសភាអឺរ៉ុប(MEPs) ចង់ពង្រឹងសហជីពសុខាភិបាល និងភាពធន់នៃប្រព័ន្ធសុខាភិបាលជាតិ សម្រាប់ការប្រឈមក្នុងថ្ងៃអនាគត។

កាលពីឆ្នាំ២០២២ គណៈកម្មាធិការពិសេសទទួលបន្ទុកជំងឺកូវីដ-១៩(COVI) បានវិភាគពីផលប៉ះពាល់នៃវិបត្តិសុខភាព បានវាយតម្លៃពីប្រសិទ្ធភាពរបស់សហភាពអឺរ៉ុប(EU) វិធានការថ្នាក់ជាតិ និងបានផ្តល់អនុសាសន៍ជាក់លាក់ ដើម្បីដោះស្រាយចន្លោះគម្លាត និងភាពទន់ខ្សោយនៅក្នុងសកម្មរបស់សហភាពអឺរ៉ុប។គណៈកម្មាធិការមួយនេះបានវាយតម្លៃមិនត្រឹមតែផលប៉ះពាល់លើប្រព័ន្ធសុខាភិបាល និងយុទ្ធនាការចាក់ថ្នាំបង្ការប៉ុណ្ណោះទេ ប៉ុន្តែក៏បានវាយតម្លៃលើផលប៉ះពាល់លើសេដ្ឋកិច្ចយ៉ាងធំធេង ប៉ះពាល់លើនីតិរដ្ឋ និងប្រជាធិបតេយ្យ ព្រមទាំងការឆ្លើយតបជាអន្តរជាតិចំពោះជំងឺរាតត្បាតជាសកលកូវីដ-១៩។ សភាអឺរ៉ុបបានពិភាក្សាដេញដោល និងអនុម័តលើរបាយការណ៍ខាងលើ ក្នុងសំឡេងគាំទ្រ ៣៨៥ ទល់នឹង១៩៣សំឡេង និងអនុបវាទ ៦៣សំឡេង។

ផែនទីបង្ហាញផ្លូវសម្រាប់សកម្មភាពនាពេលអនាគតមានវិសាលភាពលើវិស័យសំខាន់ៗចំនួន៤ រួមមាន៖ សុខាភិបាល ប្រជាធិបតេយ្យសិទ្ធិជាមូលដ្ឋាន ទិដ្ឋភាពសង្គមនិងសេដ្ឋកិច្ច និងការឆ្លើយតបជាសកលចំពោះជំងឺរាតត្បាតជាសកល។ សំណើសំខាន់ៗរួមមាន ការពង្រឹងយុទ្ធសាស្ត្រស្វ័យភាពរបស់សហភាពអឺរ៉ុបសម្រាប់ឱសថ តម្លាភាពសម្រាប់សកម្មភាពលទ្ធកម្មរួម និងការត្រួតពិនិត្យពីសភាខ្លាំងជាងមុន ទាំងនៅកម្រិតសហភាពអឺរ៉ុប និងកម្រិតថ្នាក់ជាតិ សម្រាប់ការតាក់តែងច្បាប់បន្ទាន់ៗ។

លោកស្រី Kathleen Van Brempt ប្រធានគណៈកម្មាធិការពិសេសទទួលបន្ទុកជំងឺកូវីដ-១៩ (COVI)បានថ្លែងថា បន្ទាប់ពីនេះ គឺអាស្រ័យនៅលើគណៈកម្មការអឺរ៉ុបដែលត្រូវទទួលយកអនុសាសន៍ និងពិនិត្យពិភាក្សាលើសំណើរបស់យើង ដើម្បីបង្កើតនូវសហភាពអឺរ៉ុបមួយដែលមានភាពធន់នឹងវិបត្តិជាងមុនសម្រាប់ថ្ងៃអនាគត៕

*ព័ត៌មានសភាទ្វីបអឺរ៉ុប ១៤-០៧-២៣- ឈាវ សុផាត*

ប្រែសម្រួលពី៖ https://english.news.cn/20230713/92fad240130f4373a78c81e3727616d7/c.html

# European Parliament adopts roadmap on tackling future health crises

BRUSSELS, July 13 (Xinhua) -- The European Parliament (EP) on Thursday adopted a report with a clear roadmap on how to tackle future health crises, based on the lessons learned from the COVID-19 pandemic.

Members of the European Parliament (MEPs) want to reinforce the European Health Union and the resilience of national health systems in view of future challenges, the EP said in a press release.

Last year, the EP's Special Committee on COVID-19 (COVI) analyzed the impact of the crisis, evaluated the effectiveness of European Union (EU) and national measures and made specific recommendations to address gaps and weaknesses in their actions.

The committee evaluated not only the impact on health systems and the vaccination campaign, but also the broader socio-economic impact, the impact on the rule of law and democracy, and the international response to the pandemic.

Parliament debated the report and adopted the text with 385 votes in favor, 193 against and 63 abstentions.

The roadmap for future action covers four main areas: health; democracy and fundamental rights; social and economic aspects; and the global response to the pandemic.

Key proposals include enhancing the EU's strategic autonomy for medicines; transparency for joint procurement activities; and stronger parliamentary oversight at both EU and national levels for emergency legislation.

"It is now up to the European Commission to take our recommendations and table proposals to shape a more crisis-resilient and future-proof EU," COVI Chair Kathleen Van Brempt said. ■

https://english.news.cn/20230713/92fad240130f4373a78c81e3727616d7/c.html